អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ
លេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៤)

## នីតិវិធីជំនុំជម្រះរឿងព្រហ្មទណ្ឌ
(សម្រាប់សវនាការថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៨ ម៉ោង ៩ និង ៣០នាទី )

- ភ្ញៀវចូលរួមទាំងអស់ចូលសាលសវនាការ

- ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់គេ ព្រមទាំងជនត្រូវចោទ និងសហមេធាវីការពារក្តី ចូលសាលសវនាការ

- ក្រឡាបញ្ជីជាតិប្រកាសបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្ងៃសវនាការ

-កណ្តឹងលើកទី១: សហព្រះរាជអាជ្ញាចូលកាន់សាលសវនាការ

- អ្នកសារព័ត៌មានចំនួន ៨រូប ចូលថតរូបក្នុងសាលសវនាការ

-កណ្តឹងលើកទី២: ក្រឡាបញ្ជីអញ្ជើញភ្ញៀវទាំងអស់អោយក្រោកឈរ ដោយស្រែកថា “តុលាការ” ។ ក្រុមប្រឹក្សាជំនុំជម្រះចូលក្នុងសាលសវនាការ

-ប្រធានបង្គាប់អោយអង្គុយចុះ

- អ្នកសារព័ត៌មានចាកចេញទៅវិញ ។

**<u>ប្រធានប្រកាស</u>**

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ ថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសបើកសវនាការ ដើម្បីជំនុំជម្រះរឿងព្រហ្មទណ្ឌ លេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៤) ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៧ ដែលមាន៖

១- ជនត្រូវចោទឈ្មោះ **ខៀវ សំផន** ហៅ **ហែម** សញ្ជាតិខ្មែរ ភេទ ប្រុស កើតថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង ប្រទេសកម្ពុជា ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិកូនខ្នង់ សង្កាត់អូរតាវៅ ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ប្រទេសកម្ពុជា ឪពុកឈ្មោះ ខៀវ ឡុង ម្តាយឈ្មោះ ប៉ោ គង់ ។

- ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥, មាត្រា៦, មាត្រា ២៩(ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ ។

មានមេធាវីការពារ: - លោក សាយ បូរី
- លោក Jacques VERGES

២- ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤នាក់ តំណាងដោយមេធាវី៖
- លោក ហុង គឹមសួន
- លោក ឡោ ជុនធី
- លោក នី ចាន់ឌី
- លោកស្រី ស៊ីល ស្ទូដហ្ស៊ីនស្គាយ (Silke STUDZINSKY )

**<u>ប្រធានសួរក្រឡាបញ្ជី</u>**

តើអ្នកចូលរួមសវនាការមានវត្តមានគ្រប់ចំនួនហើយឬនៅ ?

**<u>ប្រធានប្រកាស</u>**

ការជំនុំជម្រះថ្ងៃនេះ មានសមាសភាពដូចតទៅ:

១. លោក ប្រាក់ គឹមសាន ចៅក្រម

២. លោក Rowan DOWNING ចៅក្រម

៣. លោក ន័យ ថុល ចៅក្រម

៤. លោកស្រី KatinKa LAHUIS ចៅក្រម

៥. លោក ហួត វុទ្ធី ចៅក្រម

- លោក ប៉ែន ពេជ្រសាលី ចៅក្រមបំរុង

- ក្រឡាបញ្ជី: លោក ជួន សុបញ្ញា

លោកស្រី Anne Marie Burns

សហព្រះរាជអាជ្ញា: លោកស្រី ជា លាង

លោក Alexander Bates

## ប្រធានអញ្ជើញជនត្រូវចោទមកឈរមុខក្រុមចៅក្រម

លោកឈ្មោះអ្វី ? មានឈ្មោះហៅក្រៅទេ ? អាយុប៉ុន្មាន ? សញ្ជាតិអ្វី ? កើតនៅភូមិណា ? សង្កាត់ណា ? ស្រុកណា ? ខេត្តណា ? មុខរបរ ? ទីលំនៅ មុនពេលចាប់ខ្លួន ? ឪពុកឈ្មោះអ្វី ? ម្តាយឈ្មោះអ្វី ? ប្រពន្ធ ឈ្មោះអ្វី ? មានកូនប៉ុន្មាននាក់ ? តើមានពឹងអ្នកការពារ ឬ មេធាវីឬទេ ? ឈ្មោះ?

## ប្រធានអានសិទ្ធិជនត្រូវចោទ (វិធាន ២១-១ (ឃ))

*អនុលោមតាមវិធាន២១-១ (ឃ) នៃវិធានផ្ទៃក្នុង ជនត្រូវចោទត្រូវបានផ្តល់ព័ត៌មានថា ខ្លួន:*

*- ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ*

*- មានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន*

*- មានសិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន និង*

- *មានសិទ្ធិនៅស្ងៀមមិនឆ្លើយតប ។*

**<u>ប្រធានអញ្ជើញចៅក្រមរបាយការណ៍អានរបាយការណ៍</u>**

- ចៅក្រមជាតិអានរបាយការណ៍

ប្រធានអញ្ជើញភ្ញៀវ និងអ្នកដែលមិនពាក់ព័ន្ធនឹងនីតិវិធីចេញពីបន្ទប់សវនាការ ។

***<u>សវនាការសាធារណៈ</u>***

**<u>ប្រធានអញ្ជើញជនត្រូវចោទមកឈរមុខក្រចកសេះ</u>**

ប្រធានសួរប្រសិនបើជនត្រូវចោទចង់និយាយទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ដោយខ្លួនឯង ឬក៏ឲ្យមេធាវីនិយាយជំនួសក្នុងនាមខ្លួន ?

**<u>ចៅក្រមទាំងអស់អាចសួរសំណួរទៅជនត្រូវចោទ</u>**

**<u>ប្រធានអញ្ជើញសហមេធាវីធ្វើសេចក្តីសន្និដ្ឋាន</u>**

( រយៈពេល ១ ម៉ោង ៣០ នាទី សម្រាប់មេធាវីទាំងពីរ)

**<u>ប្រធានអញ្ជើញសហព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋាន</u>**

( រយៈពេល ១ ម៉ោង ៣០ នាទី សម្រាប់សហព្រះរាជអាជ្ញាទាំងពីរ)

**<u>ប្រធានអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន</u>**

( រយៈពេល ១ ម៉ោង សម្រាប់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់)

**<u>ប្រធានអនុញ្ញាតឲ្យមានសេចក្តីសន្និដ្ឋានតប</u>**

**<u>ចៅក្រមអាចសួរសំណួរ</u>**

**<u>ប្រធានសួរជនត្រូវចោទថាតើមានអ្វីចង់បន្ថែមដែរឬទេ</u>**

**<u>ប្រធានប្រកាសបញ្ចប់ការសួរដេញដោល</u>**

**<u>ប្រធានជូនព័ត៌មានអំពីការប្រកាសសាលដីកា</u>**

**<u>ប្រធានប្រកាសឲ្យក្រុមការពារនាំជនត្រូវចោទត្រឡប់ទៅមន្ទីរឃុំឃាំងវិញ ។</u>**